01374510

**Declassified to Public**
**05 April 2019**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 01 / 2017
ម៉ោង (Time/Heure): 13 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សម្ងាត់ / Confidential / Confidentiel

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៧

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **ឯកសារបន្ថែមទៀតដែលទទួលបានពីសាស្ត្រាចារ្យ Walter Heynowski**

១. នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះបានទទួលឯកសារពីសាស្ត្រាចារ្យ Walter HEYNOWSKI (2-TCW-946) ដែលរួមមាន សៀវភៅពណ៌ទឹកក្រូចដែលចងក្រងកំណត់ត្រាប្រចាំថ្ងៃរបស់អ្នកជាប់ឃុំ និង សន្លឹកទំព័រដែលដាច់ចេញពីសៀវភៅជាច្រើនសន្លឹកជាភាសាអាល្លឺម៉ង់ និង ភាសាខ្មែរ ដែលមានសភាពចាស់ខ្លាំង។ អង្គជំនុំជម្រះបានកត់សម្គាល់ថា អង្គជំនុំជម្រះមិនបានទទួលរូបថតទេ ទោះបីសាស្ត្រាចារ្យ Walter HEYNOWSKI (2-TCW-946) ធ្លាប់បានលើកឡើងថា គាត់មានរូបថតអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ក៏ដោយ (ឯកសារ E443/2)។

២. អង្គជំនុំជម្រះសាលាដំបូងបានទាក់ទងទៅសាស្ត្រាចារ្យ Walter HEYNOWSKI (2-TCW-946) ម្តងទៀត ពាក់ព័ន្ធនឹងរូបថតអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១។ នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦ សាស្ត្រាចារ្យ Walter HEYNOWSKI (2-TCW-946) បានជូនដំណឹងមកអង្គជំនុំជម្រះថា គាត់មានរូបថតអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ប្រហែល ៥០០ សន្លឹក។ រូប

ថតទាំងនោះត្រូវបានផ្ញើតាមក្រុមហ៊ុនដឹកជញ្ជូន DHL ហើយក្រឡាបញ្ជីបានទទួលកញ្ចប់ឥវ៉ាន់នោះនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦។ កញ្ចប់ឥវ៉ាន់នោះមានរូបថតពេញមួយប្រអប់ធំ ហើយយើងឃើញថា រូបថតខ្លះមានភាពចាស់ខ្លាំង ឬ ស្អិតជាប់គ្នា។

៣. អង្គភាពបណ្ណាសារ (RAU) បានយករូបថតទាំងនោះមកពិនិត្យយ៉ាងយកចិត្តទុកដាក់ ដោយមានវត្តមានក្រឡាបញ្ជីផងដែរ។ បន្ទាប់ពីបានពិនិត្យរួច បុគ្គលិកអង្គភាពបណ្ណាសារអាចធ្វើការបែងចែករូបថតជាបីប្រភេទ៖ (១) រូបថតដែលអាចផ្តាច់ចេញពីគ្នា និង យកមកថតស្កែនយ៉ាងមានសុវត្ថិភាព (២) ទំព័រដែលមិនអាចផ្តាច់ចេញពីគ្នាទាំងស្រុង តែអាចបើកបាន និង យកមកថតជារូបភាពមួយទំព័រម្តងៗ និង (៣) រូបថតដែលមានសភាពចាស់ ឬ ដែលស្អិតជាប់គ្នាខ្លាំងពេក មិនអាចយកមកថតជារូបភាព ឬ ថតស្កែនបាន។ ក្រៅពីរូបថតទាំងនោះ ក្នុងប្រអប់នោះក៏មានសំណៅដើមនៃប្រវត្តិរូបអ្នកជាប់ឃុំម្នាក់នៅមន្ទីរសន្តិសុខ ស-២១ ដែរ។

៤. អង្គជំនុំជម្រះបានបង្គាប់ដល់អង្គភាពបណ្ណាសារឱ្យបញ្ចូលឯកសារដែលបានស្កែន ឬ ថតរូបរួចរាល់ ទៅក្នុងឃ្លាំងផ្ទុកឯកសាររួម G:drive។ រូបថតផ្សេងទៀតក៏នឹងត្រូវបញ្ជូនទៅប្រធានសារមន្ទីរទួលស្លែង ដើម្បីសម្រេចថា តើអាចយករូបថតទាំងនេះមកថែរក្សា និង ថតស្កែនបានឬទេ។

៥. អង្គជំនុំជម្រះអញ្ជើញភាគីឱ្យពិនិត្យទៅលើឯកសារទាំងនេះ ដែលអាចរកបាននៅក្នុងឃ្លាំងផ្ទុកឯកសារ G:drive តាមរយៈតំណភ្ជាប់ *(link)* ដែលនឹងត្រូវផ្ញើជូនភាគីតាមអ៊ីមែល និងដាក់សំណើពាក់ព័ន្ធអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង តាមរយៈសេចក្តីសន្និដ្ឋានផ្ទាល់មាត់នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧។